# កម្មវិធីពង្រឹងឥទ្ធិពលសហគមន៍ (CEP) ២០២១

## គម្រោងពិសេសរបស់ទីភ្នាក់ងារចៃកា JICA



# សៀវភៅជំនួយ

## ស្ដីពីការលើកកម្ពស់សកម្មភាពផ្នែកលំហាត់ប្រាណសម្រាប់បុគ្គលដែលមានអូទីស្សឹម ពិការសតិបញ្ញា និងពិការភាពផ្លូវចិត្តនៅក្នុងបណ្ដាប្រទេសអាស៊ាននៅកំឡុងពេលកូវីដ-១៩



JICA

APCD

University of Tsukuba

# សៀវភៅជំនួយនេះស្តីពីសកម្មភាពផ្នែកលំហាត់ប្រាណសម្រាប់បុគ្គលដែលមានអូទីស្សឹម ពិការសតិបញ្ញា និងពិការភាពផ្លូវចិត្តនៅក្នុងបណ្តាប្រទេសអាស៊ាននៅកំឡុងពេលកូវីដ-១៩


មជ្ឈមណ្ឌលពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (APCD)

ទីក្រុងបាងកក, ប្រទេសថៃ

លេខទូរស័ព្ទ: +66 (0)23547506 • +66 (0)23547507

www.apcdfoundation.org

# មាតិកា


**អារម្ភកថា** 4

**ជំពូក ១:** សេចក្តីផ្តើម 7

**ជំពូក ២:** របៀបប្រើប្រើប្រាស់សៀវភៅជំនួយ

- គោលការណ៍នៃសៀវភៅជំនួយ 9
- វិធីធ្វើសកម្មភាពរាងកាយនៅតាមរយៈប្រព័ន្ធ Zoom 10
- ការរៀបចំសម្ភារៈបង្រៀន 14
- របៀបដឹកនាំកម្មវិធីពីចំងាយ 14

**ជំពូក ៣:** ការណែនាំពីសកម្មភាពលំហាត់ប្រាណរាងកាយ 17

**ជំពូក ៤:** សំណួរដែលត្រូវបានសួរជាញឹកញាប់ បទពិសោធន៍ទទួលបាន និងកិច្ចសហប្រតិបត្តិការនាពលអនាគត 29

**ជំពូក ៥:** មតិពីដៃគូនៃបណ្តាប្រទេសអាស៊ាន 33

**សេចក្តីបន្ថែម១:**
ឧទាហរណ៍: របៀបដំណើរការសកម្មភាពនៃសិក្ខាសាលាពីចំងាយ 35

**សេចក្តីបន្ថែម២:**
ឯកសារគោលគំនិតស្តីពីគម្រោង "ការលើកកម្ពស់ដល់ក្រុមឪពុកម្តាយរបស់កុមារដែលមានតម្រូវការពិសេសក្នុងកំឡុងពេលកូវីត១៩" 38

# អារម្ភកថា

ខ្ញុំមានសេចក្ដីសោមនស្សរីករាយ ហើយសូមអបអរសាទរអ្នកចំពោះភាពជោគជ័យនៃការរៀបចំសិក្ខាសាលាទាំងបីនេះ ក៏ដូចជាបានបង្កើតអោយមានសៀវភៅជំនួយនេះឡើង ។

គម្រោងនេះត្រូវបានអនុវត្តក្រោមកម្មវិធីមួយដែលហៅថាកម្មវិធីពង្រឹងឥទ្ធិពលសហគមន៍(**CEP**) របស់ទីភ្នាក់ងារ JICA ដែលមានបំណងគាំទ្រនូវសកម្មភាពថ្នាក់មូលដ្ឋាននៅតាមសហគមន៍ស្របតាមកាលៈទេសៈនូវការរីករាលដលនជម្ងឺកូវីដ-១៩។ ខ្ញុំពិតជាមានការចាប់អារម្មណ៍យ៉ាងខ្លាំងនៅពេលដែលបានឃើញកុមារដែលមានតម្រូវការពិសេសអាចធ្វើលំហាត់ប្រាណ និងលេងល្បែងកំសាន្តផ្សេងៗគ្នាជាមួយនឹងស្នាមញញឹមនៅក្នុងសិក្ខាសាលា និងឈុតវីដេអូរ ។ ខ្ញុំជឿជាក់ថាសៀវភៅជំនួយនះនឹងមានតម្លៃសម្រាប់កុមារទាំងអស់ ដែលមានតម្រូវការពិសស និងឪពុកម្ដាយរបស់ពួកគេនៅក្នុងបណ្ដាប្រទេសអាស៊ាន ព្រោះវាជាការចងក្រងចំណេះដឹង បទពិសោធន៍ របស់អ្នកចូលរួមក្នុងគម្រោង និងជាពិសេសការផ្ដល់ក្ដីស្រឡាញ់ចំពោះកុមារ ។ លទ្ធផលដែលលេចធ្លោបំផុតនៃគម្រោងនះគឺការពង្រឹងបណ្ដាញ និងការតភ្ជាប់ទំនាក់ទំនងក្នុងចំណោមបណ្ដាប្រទេសក្នុងអាស៊ាន ។ យើងបានឃើញថា យើងអាចប្រាស្រ័យទាក់ទងជាមួយគ្នា ធ្វើលំហាត់ប្រាណជាមួយគ្នា និងសើចជាមួយគ្នាសូម្បីតែជំងឺរាតត្បាតកូវីដ-១៩ រីករាលដាលក៏ដោយ ។



ខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (APCD) លោកបណ្ឌិត សាវី (Dr. Sawae) និងក្រុមធនធានមនុស្សជនជាតិជប៉ុនមកពីសកលវិទ្យាល័យ Tsukuba ក៏ដូចជាអង្គការដទៃទៀតទាំងអស់ដែលបានចូលរួមសម្រាប់ការខិតខំនិងការចូលរួមចំណែករបស់គម្រោងនះ ។

ខ្ញុំសង្ឃឹមថាអ្នកនឹងរីករាយជាមួយលំហាត់ប្រាណទាំងនេះជាមួយសៀវភៅមួយនេះនៅផ្ទះរបស់អ្នក!

**លោក Morita Takahiro**
**ប្រធានតំណាងការិយាល័យអង្គការ JICA**
**ប្រចាំប្រទេសថៃ**

ខ្ញុំបានសិក្សា និងសាកល្បងនូវការអភិវឌ្ឍម៉ូតូសម្រាប់ជាជំនួយដល់កុមារពិការនៅសកលវិទ្យាល័យ ស្សុគូបាក់ (Tsukuba University) ក្នុងប្រទេសជប៉ុន។

នៅចុងខែមេសាឆ្នាំ២០២០ សាលារៀន និងស្ថាប័នជាច្រើនទៀតនៅក្នុងប្រទេសជប៉ុនត្រូវបានគេតម្រូវអោយផ្អាកដំណើរការ មិនឱ្យចេញទៅខាងក្រៅហើយសកម្មភាពដែលត្រូវបានរៀបចំឡើងសម្រាប់កុមារដែលមានពិការភាពនៃការលូតលាស់ត្រូវបានបិទ។

ភ្លាមៗបន្ទាប់ពីការបិទទ្វារឪពុកម្តាយរបស់កុមារដែលមានពិការភាពដែលជាអ្នកចូលរួមក្នុងសកម្មភាពរបស់យើងបានត្អូញត្អែរថា កូនៗរបស់ពួកគេញ៉ាំច្រើនពេកហួសប្រមាណ នៅពេលពួកគេនៅផ្ទះ។ ពួកគេមិនចង់ធ្វើអ្វីមួយនោះទេ ពួកគេមានអារម្មណ៍ធុញថប់ ព្រោះពួកគេលែងមានសកម្មភាពធ្វើទៅតាមទម្លាប់ដូចរាល់ដងទៀតហើយ ដែលនេះធ្វើអោយ ពួកគេកាន់តែយ៉ាប់ទៅៗ។ ឪពុកម្តាយគាត់ក៏មានអារម្មណ៍តានតឹងនិងបារម្ភអំពីវិធីដោះស្រាយក្នុងស្ថានភាពនេះដែរ ដែលគាត់មិនធ្លាប់បានជួបពីមុនមក។ ដូច្នេះខ្ញុំបានពិភាក្សាជាមួយមិត្តរួមការងាររបស់ខ្ញុំ ហើយបានបង្កើតផែនការដើម្បីជួយកុមារពិការក្នុងការលូតលាស់អោយរីករាយនឹងសកម្មភាពរាងកាយ និងរស់នៅក្នុងរបៀបរស់នៅប្រកបដោយសុខភាពល្អ នៅក្នុងកាលៈទេសៈទាំងនេះ។ ផែនការនេះគឺ ការធ្វើសកម្មភាពតាមប្រព័ន្ធអ៊ីនធឺណេត។ ទោះបីខ្ញុំមិនមានបច្ចេកវិទ្យាជឿនលឿន ប៉ុន្តែខ្ញុំបានរៀនអំពីបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងតាមរយៈការសាកល្បង និងការជៀសវាងកំហុស ដែលផ្តោត លើកុមារនិងឪពុកម្តាយជាសំខាន់។ ភាពចាំបាច់នោះគឺជា ប្រភពដើមនៃការរៀនសូត្រ។

ខ្លឹមសារនៃសៀវភៅជំនួយនេះគឺផ្អែកលើបទពិសោធន៍របស់ខ្ញុំ និងមិត្តរួមការងាររបស់ខ្ញុំ។ ជាការពិតណាស់ អ្នកមិនចាំបាច់ ធ្វើវាអោយដូចតាមការសរសេរណែនាំនៅក្នុងសៀវភៅនេះទាំងស្រុងនោះទេ អ្នកអាចកែប្រែខ្លឹមសារខ្លះៗដើម្បីធ្វើឱ្យវាសប្បាយរីករាយសម្រាប់កុមារក្នុងការចូលរួមជាងនេះ។ ខ្ញុំនិងមិត្តរួមការងាររបស់ខ្ញុំបានព្យាយាម និងទទួលបរាជ័យជាច្រើនដង ដូច្នេះ យើងចង់អោយអ្នកសាកល្បង អោយបានច្រើនដងនិងលើកស្ទួយខ្លឹមសារទៅជារបស់ដែលល្អប្រសើរសម្រាប់កុមារ។ ការសាកល្បងអភិវឌ្ឍនូវខ្លឹមសារមាតិការបស់អ្នក នឹងក្លាយជាប្រភពនៃការអភិវឌ្ឍសម្រាប់ពួកយើងទាំងអស់គ្នា។



**P.h.D Sawae Yukinori**
Associate Professor
Clinical Developmental Psychologist, Faculty of Health & Sport Sciences
The University of Tsukuba

មជ្ឈមណ្ឌលពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (APCD) សូមកោតសរសើរដល់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) និងសកលវិទ្យាល័យ Tsukuba ចំពោះការសហការនិងការចូលរួមចំណែកដ៏ធំធេងនៅក្នុងគម្រោង “ លើកកម្ពស់សកម្មភាពរាងកាយសម្រាប់កុមារដែលមានអូទីស្សឹម ពិការសតិបញ្ញា និងពិការភាពផ្លូវចិត្តនៅក្នុងបណ្តាប្រទេសអាស៊ានដើម្បីដោះស្រាយក្នុងអំឡុងពេលកូវីដ-១៩” ។

លទ្ធផលសំខាន់នៃគម្រោងនះគឺជាសៀវភៅជំនួយសម្រាប់ផ្តល់អំណាចដល់ឪពុកម្តាយរបស់កុមារពិការដែលមើលមិនឃើញដើម្បីលើកកម្ពស់សកម្មភាពរាងកាយរបស់កុមារ។ សៀវភៅជំនួយមានជាភាសាអង់គ្លេសក៏ដូចជាភាសារបស់បណ្តាប្រទេសសមាជិកអាស៊ាន។ យើងជឿជាក់ថាសៀវភៅជំនួយនះនឹងផ្តល់នូវធនធានសំខាន់ដើម្បីជួយអ្នកនៅក្នុងតំបន់អាស៊ានរបស់យើងឱ្យមានសុខភាពល្អក្នុងកំឡុងពេលនិងក្រោយពេលការឆ្លងរាតត្បាតនៃជម្ងឺកូវីដ-១៩ ។

ពួកយើងសូមថ្លែងអំណរគុណដល់គ្រប់ដៃគូនៅក្នុងបណ្តាប្រទេសអាស៊ានទាំងអស់រួមទាំង បណ្តាញអូទីស្សឹមក្នុងបណ្តាប្រទេស អាស៊ាន បណ្តាញសហពន្ធ័ពិការសតិបញ្ញានៅអនុតំបន់មេគង្គ សមាគមជំងឺផ្លូវចិត្តប្រចាំប្រទេសថៃ សមាគមន៍ជនពិការសតិបញ្ញានៅប្រទេសថៃ និងសមាគមន៍បង្រួបបង្រួមអ្នកមានអូទីស្សឹមប្រទេសថៃ។ ពួកគេបានចូលរួមយ៉ាងសកម្មនៅ ក្នុងសិក្ខាសាលានីមួយៗហើយស្នើរឱ្យមានការកែលម្អនៅក្នុងសៀវភៅជំនួយនេះ។ជាអកុសល សហសេរិកមកពីប្រទេសព្រុយណេ និងសិង្ហបុរីមិនអាចចូលរួមក្នុងគម្រោងនេះបាន។ យើងជឿជាក់ថា កម្មវិធីនេះនឹងកាន់តែល្អឥតខ្ចោះប្រសិនបើប្រទេសទាំងពីរបានចូលរួម។

យើងជឿជាក់ថាគម្រោងនេះនឹងធ្វើជាគំរូមួយសម្រាប់វិធីធ្វើការជាមួយដៃគូនិងបណ្តាញផ្សេងៗនៅក្នុងប្រទេសជប៉ុននិងបណ្តាប្រទេសអាស៊ានដើម្បីធ្វើការអភិវឌ្ឍសម្រាប់ជនពិការនិងមនុស្សចាស់ក្នុងពេលមានវិបត្តិកូវីដ-១៩ នៅក្នុងតំបន់របស់យើង។



**លោក Piroon Laismit**
**នាយកប្រតិបត្តិ APCD**

# ជំពូក 1

## សេចក្តីផ្តើម

### តើកម្មវិធី CEP ជាអ្វី?

កម្មវិធីពង្រឹងឥទ្ធិពលសហគមន៍(CEP)បានបង្កើតកម្មវិធីសហប្រតិបត្តិការបច្ចេកទេសដើម្បីទ្រទ្រង់និងលើកកម្ពស់ជល់កុមារងាយរងគ្រោះរួមទាំងជនពិការ (PWDs) ដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាតកូវីដ-១៩ នៅក្នុងកម្រិតមូលដ្ឋាន។

### តើធនធានត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច?

ថវិកាសម្រាប់ផ្គត់ផ្គង់គម្រោងCEPត្រូវបានផ្តល់ដោយការិយាល័យទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) នៅប្រទេសថៃ។APCD បានសម្របសម្រួលនិងអនុវត្តគម្រោង ហើយសកលវិទ្យាល័យ Tsukuba បានផ្តល់ការផ្គត់ផ្គង់ផ្នែកបច្ចេកទេសសម្រាប់ការផ្ទេរចំណេះដឹង។ ភាគីទាំងបីធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាលើផែនការ ការអនុវត្ត និងការត្រួតពិនិត្យ។

## ហេតុអ្វីយើងអនុវត្តគម្រោង CEP សម្រាប់កុមារពិការនិងគ្រួសាររបស់ពួកគេក្នុងបណ្តាប្រទេសអាស៊ានដើម្បីដោះស្រាយក្នុងអំឡុងពេលកូវីដ-១៩?




*Japanese resource person team*

ក្នុងកំឡុងពេលជំងឺរាតត្បាតកូវីដ-១៩ មានកុមារជាច្រើនស្ថិតក្នុងស្ថានភាពមិនល្អទាំងផ្លូវកាយ ទាំងផ្លូវចិត្តដែលជាក្តីកង្វល់របស់គ្រួសារពួកគេ។ ពួកគេបរិភោគអាហារដែលមិនល្អចំពោះសុខភាព អង្គុយឬដេកលេងឧបករណ៍ចល័តហើយចូលគេង។ សកម្មភាពដដែលៗនេះ អាចនាំអោយពួកគេអាចប្រឈមនឹងការឡើងទម្ងន់ហើយធាប់ខឹង។ លើសពីនេះទៀតពួកគេមិនមានទំនាក់ទំនងជាមួយគ្រួសារនោះទេហើយអាចធ្វើឱ្យពួកគេបង្ហាញពីភាពខកចិត្តចំពោះសមាជិកគ្រួសារទៀតផង។

## “អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនពិការ”
## មាត្រា៣០: ការចូលរួមក្នុងជីវិតវប្បធម៌ ការកំសាន្ត ការលំហែនិងកីឡា

ជនពិការមានសិទ្ធិដូចអ្នកដទៃទៀតដែរក្នុងការចូលរួមនិងរីករាយជាមួយសិល្បៈ កីឡា ល្បែងកំសាន្តភាពយន្តនិងសកម្មភាពកំសាន្តផ្សេងៗទៀត។ដូច្នេះសកម្មភាពលំហាត់ប្រាណគួរតែអាចចូលដំណើរការបានសម្រាប់មនុស្សគ្រប់គ្នារួមទាំងកុមារពិការដោយ មិនគិតពីពេលវេលាឬទីកន្លែង។ សៀវភៅជំនួយនេះគឺជាឧបករណ៍មួយដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់កុមារដែលមានអូទីស្សឹម ពិការសតិបញ្ញានិងពិការភាពផ្លូវចិត្តជាមួយសមាជិកគ្រួសាររបស់ពួកគេដោយ ប្រើប្រាស់ប្រព័ន្ធពីចំងាយមួយក្នុងកំឡុងស្ថានភាពកូវីដ-១៩ ។ សូមរីករាយនឹងលំហាត់ប្រាណ និងធ្វើឱ្យកូនៗ របស់យើងទទួលបានស្នាមញញឹម។ តោះទៅ!

# ជំពូក 2

## របៀបប្រើប្រាស់សៀវភៅជំនួយ

- គោលការណ៍សៀវភៅជំនួយ

1) ក្នុងកំឡុងពេលនៃការបិទខ្ទប់ជំងឺរាតត្បាតកូវីដ-១៩ សៀវភៅជំនួយនេះមានគោលបំណងលើកកម្ពស់គុណភាពជីវិត និងលើកកម្ពស់របៀបរស់នៅដែលមានសុខភាពល្អតាមរយៈសកម្មភាពលំហាត់ប្រាណ។

2) សៀវភៅជំនួយនេះមានគោលបំណងលើកទឹកចិត្តឪពុកម្តាយសមាជិកគ្រួសារ ឬអ្នកអាណាព្យាបាលឱ្យគាំទ្រ និងលេងជាមួយកូនៗរបស់ពួកគេនៅផ្ទះ។

3) សៀវភៅជំនួយនេះប្រើសម្រាប់ជាទំនាក់ទំនងដើម្បីផ្តល់ចំណេះដឹងនិងលំហាត់ប្រាណជាក់ស្តែងក្នុងកំឡុងពេលនៃការបិទខ្ទប់កូវីដ-១៩ ដែលការបណ្តុះបណ្តាលដោយផ្ទាល់ និងការធ្វើដំណើរទៅបរទេសមិនអាចធ្វើទៅបាន។

4) ទោះបីជាចំណងជើងគម្រោងគឺ "ការលើកកម្ពស់ផ្នែកលំហាត់ប្រាណសម្រាប់បុគ្គលដែលមានអូទីស្សឹម ពិការសតិបញ្ញា និងពិការផ្លូវចិត្ត" ប៉ុន្តែនៅពេលយើងយោងពួកគេនៅក្នុងសៀវភៅជំនួយនេះយើងប្រើសកម្មភាពពាក្យ "កូនៗរបស់អ្នក" ឬ "កូនអ្នក" ។

តោះ! បង្កើតសកម្មភាពលំហាត់ប្រាណតាមអ៊ិនធឺណេតដោយប្រើសំភារៈ
ដែលគ្រប់គ្នាអាចមាននៅផ្ទះ។

## • វិធីធ្វើសកម្មភាពរាងកាយនៅតាមរយៈកម្មវិធី Zoom

Zoom គឺជាកម្មវិធីទំនាក់ទំនងតាមទូរស័ព្ទដែរ៖

- មិនគិតថ្លៃក្នុងរយៈពល ៤៥ នាទី
- ងាយស្រួលនិងរីករាយក្នុងការប្រើប្រាស់
- ពេញនិយម
- ប្រើប្រាស់ទូទាំងសកល

## • វិធីចុះឈ្មោះគណនីរបស់អ្នក?

1. ទាញយកកម្មវិធីនៅលើកំព្យូទ័រឧបករណ៍ចល័តដែលអ្នកអាចចុះឈ្មោះដោយ៖
    - បង្កើតគណនីជាមួយអ៊ីម៉េលនិងពាក្យសម្ងាត់របស់អ្នក។
    - ចូលដោយបើកមុខងារអេសអេសអូ SSO ការចូលតែម្តង (Single Sign-On) ឬគណនីហ្គូហ្គល(Google) ឬហ្វេសប៊ុក (Facebook)របស់អ្នក។
2. ចូល

## • វិធីចូលទៅកាន់កម្មវិធី?

ចូលដោយប្រើតំណភ្ជាប់ (URL) ដែលផ្តល់ដោយម្ចាស់ជំណើរការ។ ចុចលើតំណភ្ជាប់ដែលផ្តល់ដោយម្ចាស់ជំណើរការដើម្បីចូលរួម

ជំហានទី១៖ បើកកម្មវិធី **Zoom** ហើយចុចលើរូបតំណាងអោយពាក្យ'ចូលរួម'




ជំហានទី២៖បំពេញ ឬភ្ជាប់នូវលក្ខខណ្ឌសម្គាល់នៅក្នុងប្រអប់លេខសម្គាល់ ហើយបំពេញឈ្មោះរបស់អ្នកបន្ទាប់មកចុចពាក្យជា 'ចូលរួម', **'Join'**



# វិធីរៀបចំការប្រជុំដោយការកំណត់ថ្ងៃទុកមុន

ជំហានទី១: ដើម្បីរៀបចំការប្រជុំសូមចុចលើរូបតំណាងប្រទិតិន **'Schedule'** នៅលើកម្មវិធី



ជំហានទី២:បំពេញបែបបទព័ត៌មានស្ដីពីតារាងពេលវេលាប្រជុំ **‘Schedule Meeting’** ដែលចេញមក




ជំហានទី៣: បន្ទាប់ពីបំពេញរួចរាល់ហើយ ចុចលើពាក្យថា **‘Schedule’** នៅខាងក្រោមបំផុតហើយខាងស្ដាំ

# ការរៀបចំសម្ភារៈបង្រៀន

យើងណែនាំអោយប្រើសម្ភារៈដែលមាននៅផ្ទះសម្រាប់ចូលរួម។សម្ភារៈដែលគួររៀបចំ មានដូចជា៖ ក្រដាសកាសែត ម៉ាស ស្កុត ថង់ប្លាស្ទិក កម្រាលហាត់យូហ្គា និងផ្សេងៗទៀត។សកម្មភាពលំហាត់ប្រាណនះគួរតែបង្កើតភាពសប្បាយរីករាយសម្រាប់កុមារ មិនត្រូវការចំណាយច្រើនហើយជាអ្វីមួយដែលក្មេងៗចង់ធ្វើដោយខ្លួនឯង។ ទន្ទឹមនឹងនេះសម្ភារៈអេឡិចត្រូនិកដែលត្រូវការសម្រាប់ទំនាក់ទំនងពីចំងាយមានដូចជា កុំព្យូទ័រ អ៊ីម៉េល ការតភ្ជាប់អ៊ីនធឺណេត និងកម្មវិធី **Zoom**។

## របៀបដឹកនាំកម្មវិធីពីចំងាយ

- បង្កើតកម្មវិធី
- ផ្ញើរសារលិខិតអញ្ជើញទៅអ្នកចូលរួមឬអ្នកដែលចាប់អារម្មណ៍ដោយភ្ជាប់នូវលីងតំណភ្ជាប់ចូលរួម
- រៀបចំផែនការសកម្មភាពសម្រាប់សិក្ខាសាលា
- ណែនាំកម្មវិធី និងពន្យល់ដល់អ្នកចូលរួមនូវអ្វីដែលពួកគេនឹងធ្វើ
- ផ្តល់ការពន្យល់ ឬការបកប្រែប្រសិនបើចាំបាច់
- ផ្តល់នូវមាតិកាទៅកាន់អ្នកចូលរួម
- បញ្ចប់ដោយមាតិកានិងផ្តល់ព័ត៌មានអំពីសកម្មភាពនាពេលខាងមុខ

ព័ត៌មានបន្ថែមស្តីពីវិធីសាស្រ្តដំណើរការនិងឧទាហរណ៍នៃកម្មវិធីមាននៅក្នុងផ្នែក "សេចក្តីបន្ថែម" នៃសៀវភៅជំនួយនេះ។

# ជំពូក 3

# ការណែនាំពីសកម្មភាពលំហាត់ប្រាណរាងកាយ

យើងសូមថ្លែងអំណរគុណចំពោះការសហការរបស់បុគ្គលិកជនជានមនុស្សជនជាតិជប៉ុន និងដៃគូអាស៊ានរបស់យើងដើម្បីផ្ដល់នូវការផ្ដត់ផ្គង់និងចែករំលែកមតិយោបល់របស់ពួកគេ ដើម្បីអភិវឌ្ឍសកម្មភាពសាមញ្ញសប្បាយរីករាយនិងអស្ចារ្យសម្រាប់សៀវភៅជំនួយនេះ។

# 1) ការកម្ដៅសាច់ដុំ/ការសម្រួលអារម្មណ៍ ចលនាទី១

វិធី: សូមលាតសន្ធឹងដៃរបស់អ្នកដើម្បីការពារការរងរបួស!




POINT!

- ត្រូវប្រាកដថារាងកាយទាំងមូលរបស់អ្នកបង្ហាញនៅលើអេក្រង់!
- ដាក់ម្រាមដៃរបស់អ្នកនៅលើដៃម្ខាងទៀតដើម្បីបង្ហាញការរាប់ចំនួនវិនាទី

## ប្រសិនបើចលនាពិបាកពេក

អ្នកអាចបំបែកវាជាជំហានតូចៗ៖

១. លាតត្រដាងដៃឆ្វេងរបស់អ្នកឆ្លងកាត់ទ្រូងរបស់អ្នក

២. លាតត្រដាងដៃស្ដាំរបស់អ្នកនៅខាងក្រោមដៃឆ្វេងដោយខ្នងដៃបែរមុខទៅរកកាមេរ៉ា

៣. ពត់ដៃស្ដាំរបស់អ្នកនិងរក្សាដៃឆ្វេងឱ្យនៅនឹងកន្លែង

៤. ធ្វើដដែលៗតែប្តូររវាងដៃឆ្វេងនិងស្ដាំ។

CLICK!

ភ្ជាប់លីងវីដអូរបស់អ្នកនៅទីនេះ
https://www.youtube.com/watch?v=zCs25aAWuNY

# 2) ការកម្តៅសាច់ដុំ/ការសម្រួលអារម្មណ៍

## ចលនាទី២

វិធី: សូមលាតសន្ទឹងផ្នែកជងខ្លួនរបស់អ្នកដើម្បីការពារការរងរបួស!




**POINT!** សរសើរកូនរបស់អ្នកដោយប្រាប់ពួកគេថា “ធ្វើបានល្អណាស់” ប្រសិនបើពួកគេធ្វើចលនាដែលដូចគ្នាឬស្រដៀងនឹងរូបភាព

## ប្រសិនបើចលនាពិបាកពេក

ចែកវាទៅជាជំហានតូចៗជាច្រើនស្រដៀងនឹងជំហានដែលបានបង្ហាញខាងលើ

CLICK! ភ្ជាប់លីងវីដេអូរបស់អ្នកនៅទីនេះ:
https://www.youtube.com/watch?v=BAeT6TGpSVA

# 3)ការកម្តៅសាច់ដុំ/ការសម្រួលអារម្មណ៍

## យូហ្គា- ការទប់លំនឹង

វិធី:  សូមព្យាយាមធ្វើយូហ្គាខុសៗគ្នាជាច្រើនក្នុងការទប់លំនឹងរបស់អ្នកដើម្បីការពារការរងរបួស និងជាការលំហែរ!



ការទប់លំនឹងដោយការឈរត្រង់



ការទប់លំនឹងដោយ លត់ជង្គង់ ត្រដាងជើងម្ខាងនិងលើកដៃឡើងលើ



ពត់ខ្លួនទៅក្រោយ

**កំណត់ពេលវេលាទៅតាមស្ថានភាពសុខភាពរបស់កូនអ្នកដើម្បីឱ្យគាត់ហាត់ប្រាណបានស្រួល**

POINT

ខណៈពេលដែលលាតសន្ទឹងដងខ្លួន យើងណែនាំឱ្យអ្នកដាក់កាមេរ៉ាមើលឃើញរាងកាយទាំងមូល ដោយផ្អែកលើចលនានីមួយៗអ្នកក៏អាចកសំរួលមុំកាមេរ៉ាដើម្បីឱ្យវាអាចមើលឃើញបំផុត។

### ប្រសិនបើចលនាពិបាកពេក



ព្យាយាមប្រើជញ្ជាំងឬជំនួយពីអ្នកដែលនៅក្បែរដើម្បីទប់។



ភ្ជាប់លីងវីដេអូរបស់អ្នកនៅទីនេះ

CLICK!

https://www.youtube.com/watch?v=_UnwuiFBNgk

# 4) ល្បែងត្រិះ

វិធី៖ បំពេញខ្យល់ក្នុងថង់ប្លាស្ទិចដែលអ្នកអាចរកនៅផ្ទះបាន ដើម្បីបង្កើតប៉េងប៉ោង បិទវាយ៉ាងតឹង ហើយបោះវាទៅលើក្នុងកម្រិតមួយដែលអ្នកអាចប៉ះបាន



បំពេញខ្យល់ក្នុងថង់ប្លាស្ទិចអោយពេញ



បោះឡើងលើហើយត្រិះដោយដៃ



ត្រិះវាដោយកែងដៃរបស់អ្នក

**សាកល្បងមើលថាតើអ្នកអាចត្រិះវាបានប៉ុន្មានដងក្នុងរយៈពេល ២០ វិនាទី**

POINT **សរសើរកូនអ្នកដោយនិយាយថា “ធ្វើបានល្អណាស់” ទោះបីពួកគេធ្វើបានតែមួយក៏ដោយ**

**ប្រសិនបើចលនាពិបាកពេក**

- អ្នកអាចប្រើរបស់ផ្សេងទៀតជំនួសដូចជាប៉េងប៉ោងជាដើម

**ប្រសិនបើចលនាស្រួលពេក**

- ក្រៅពីត្រិះដោយដៃអ្នកអាចព្យាយាមត្រិះជាមួយផ្នែកផ្សេងទៀតដូចជាកែងដៃ ស្មា ជើងនិងក្បាល។

CLICK! ភ្ជាប់លីងវីដេអូរបស់អ្នកទីនេះ
https://www.youtube.com/watch?v=zh4ndJu19Yg&t=3s

# 5 ) ល្បែងរក្សាលំនឹង

វិធី៖ នេះគឺជាល្បែងមានតុល្យភាពដែលប្រើរបស់របរដែលអ្នកមាននៅផ្ទះជាឧទាហរណ៍ក្រដាសកាសែត។ តោះយើងប្រកួតប្រជែងនឹងខ្លួនឯងដើម្បីដឹងថាតើយើងអាចទ្ររបស់របរផ្សេងៗបានយូរប៉ុណ្ណា!



ដំបងធ្វើពីកាសែតមូលចូលគ្នា



ដបទឹក



សៀវភៅ

### ប្រសិនបើចលនាពិបាកពេក

- រកអ្វីដែលងាយស្រួលក្នុងការរក្សាលំនឹង (ដូចជាកែវប្លាស្ទិច)។

### ប្រសិនបើចលនាស្រួលពេក

- ព្យាយាមអោយមានតុល្យភាពនៅលើផ្នែកផ្សេងៗនៃរាងកាយដូចជាក្បាល ខ្នង ជើងជាដើម។

CLICK!

ភ្ជាប់លីងវីដេអូរបស់អ្នកទីនេះ:

https://www.youtube.com/watch?v=uWvkMkaJ7-g&t=3s

# 6 )បោះជំហានទៅចំហៀង

វិធី ៖ នេះគឺជាល្បែងមួយដែលក្នុងនោះមានខ្មៅដៃឬប៊ិចចំនួន ៦ ត្រូវបានដាក់នៅចម្ងាយពីរឬបីម៉ែត្រពីពែងនៅកណ្តាល ។មើលទៅតាមសញ្ញាព្រួញក្នុងរូប  រួចដាក់ខ្មៅដៃឬប៊ិចចូលទៅក្នុងពែងម្តងមួយៗខណៈពេលដែលកំពុងបោះជំហានទៅចំហៀង ។



រួចរាល់ ? ចាប់ផ្តើម

ចាប់ខ្មៅដៃឬប៊ិច

ដាក់វាទៅក្នុងកែវ



### ប្រសិនបើចលនាពិបាកពេក

- ដាក់ប្រវែងចន្លោះរវាងពែងនិងខ្មៅដៃឬប៊ិចខ្លីជាងមុន

### ប្រសិនបើចលនាស្រួលពេក

- បោះជាជំហានផ្សេងៗគ្នាដូចជាជំហានជើងតែមួយរឺបង្វិលខ្លួនជំនួសជំហានបន្ទាប់មកសង្កេតមើលចលនារបស់កូនៗអ្នក ។

ភ្ជាប់លីងវីដេអូរបស់អ្នកទីនេះ

CLICK!

https://www.youtube.com/watch?v=ggSWLe_M1ks&t=4s

# 7) ល្បែងរង្វង់ខ្សែ

វិធី៖ នេះគឺជាល្បែងមួយដែលរង្វង់ជាក្រដាសត្រូវបោះទៅក្នុងដៃ ជើងឬក្បាលអ្នកដែលឈរនៅចម្ងាយពីរឬបីម៉ែត្រ។




បោះរង្វង់៤ទៅផ្នែកទាំងបួននៃរាងកាយ(ដៃពីរ ក្បាលនិងជើង) បន្ទាប់មកមើលថាតើមានផ្នែកណាខ្លះអាចដាក់រង្វង់បាន។ផ្នែកមួយស្មើនឹងមួយពិន្ទុ។ទោះបីជាកូនរបស់អ្នកបោះរង្វង់ពីរឬច្រើននៅលើផ្នែកតែមួយពួកគេនឹងទទួលបានតែមួយពិន្ទុប៉ុណ្ណោះ។

**ប្រសិនបើចលនាពិបាកពេក**

- កាត់បន្ថយចម្ងាយរវាងអ្នកបោះនិងអ្នកចាប់។
- ធ្វើរង្វង់អោយធំជាងមុន

**ប្រសិនបើចលនាស្រួលពេក**

- បង្កើនចម្ងាយរវាងអ្នកបោះនិងអ្នកចាប់។
- អោយអ្នកចាប់ផ្លាស់ទីឬមានចលនា។

ភ្ជាប់លីងវីដេអូរបស់អ្នកទីនេះ

CLICK! https://www.youtube.com/watch?v=j2dEs29Vy0U&t=11s

# ៨ ) ល្បែងលោតខ្សែពួរ

វិធី៖ តោះលោតចូលក្នុងចន្លោះរង្វង់ធំមួយធ្វើពីក្រដាសដូចជាលោតខ្សែ។



បង្កើតរង្វង់ក្រដាសដ៏ធំមួយ

លោតចូលក្នុងចន្លោះរង្វង់នៅពេលរង្វង់ទៅដល់ជើងរបស់អ្នក!

**សូមប្រកួតប្រជែងនឹងខ្លួនអ្នក ថាតើអ្នកអាចលោតបានចំនួនប៉ុន្មានដងក្នុងរង្វង់ក្នុងរយៈពេល២០វិនាទី។**

**ប្រសិនបើចលនាពិបាកពេក**

- បោះជើងមួយទៅក្នុងរង្វង់ក្នុងពេលតែមួយ។
- ប្រើរង្វង់អោយធំជាងមុន។

**ប្រសិនបើចលនាស្រួលពេក**

- ព្យាយាមលោតថយក្រោយទៅក្នុងរង្វង់
- កំណត់រយៈពេលវែងជាងនេះ។

CLICK!

ភ្ជាប់លីងវីដេអូរបស់អ្នកទីនេះ៖

https://www.youtube.com/watch?v=iWh2MvkEH_Q&t=5s

# 9) ល្បែងវាយសត្វចម្លែក

វិធី៖ នេះជាល្បែងមួយដែលកុមារអាចវាយ "សត្វចម្លែក" ដោយឃ្លាំងដាល់និងទាត់ពួកគេ ។បិសាចនោះនឹងបង្ហាញខ្លួននៅជ្រុងផ្សេងៗនៃអេក្រង់ហើយក្មេងៗត្រូវដាល់និងទាត់ពួកគេរហូតពួកគេទៅបាត់ ។



បង្កើតស្រោមមុខ





កុមារត្រូវដាល់និងទាត់សត្វចម្លែកនៅលើអេក្រង់ ។

កុមារៗត្រូវដឹងពីរបៀបដាល់និងទាត់មុនពេលលេងហ្គេម ។

**នេះជាវិធីល្អប្រសើរជាងមុនក្នុងការដឹកនាំការលេងល្បែងនេះ ដោយតាមរបៀបដូចខាងក្រោម:**

• អ្នកចូលរួមត្រូវតែទាត់បិសាចពណ៌ក្រហមហើយដាល់បិសាចពណ៌ខៀវ។

**ប្រសិនបើស្រួលពេក**

• ធ្វើអោយសត្វចម្លែកសើចដោយកុមារអាចធ្វើមុខកំប្លែងឬព្យាយាមបង្កើតសញ្ញានៃ "ក្ដីស្រលាញ់": (សូមមើលរូបភាពនៅខាងស្ដាំ) ដើម្បីអោយសត្វចម្លែកក្លាយជារួសរាយរាក់ទាក់ជាមួយពួកគេ ។

CLICK!

ភ្ជាប់លីងវីដេអូរបស់អ្នកទីនេះ:

https://www.youtube.com/watch?v=GAHkxGWGm-I&t=2s

# 10)របាំប្រពៃណីថៃ រាំវង់ (Ramwong)

វិធី៖ “ងាមសាងដួន” ( ពន្លឺព្រះចន្ទដ៏ស្រស់ស្អាត ) គឺជាចម្រៀងប្រជាប្រិយរបាំរបស់ថៃ ។អ្នករាំបោះជំហានឆ្ពោះទៅរកចង្វាក់នៃបទចម្រៀងហើយរាំជុំវិញជារង្វង់ ។យើងអាចបង្កើតដៃគូ ហើយរាំព័ទ្ធជុំវិញគ្នា ។





សកម្មភាពនេះជួយអោយកុមារសម្រាកនិងរៀនពីចលនារាង

**ចលនានៃការរាំអាចជួយដល់ការ៖**

- អភិវឌ្ឍន៍រាងកាយ ផ្តល់រំញោចដល់ខួរក្បាល និងជំរុញដំណើរការនៃសាច់ដុំ
- អនុវត្តលើការកំណត់អត្តសញ្ញាណរវាងខាងឆ្វេង និងខាងស្តាំ
- និងធ្វើអោយកុមារមានអារម្មណ៍ធូរស្បើយនិង មានអន្តរកម្មល្អជាមួយ ឪពុកម្តាយ

**ប្រសិនបើចលនាពិបាកពេក**

- ធ្វើចលនាដៃដោយសេរី
- គ្រាន់តែលើកដៃឡើង ចុះពេលដើរក្នុងរង្វង់

CLICK!

ភ្ជាប់លីងវីដេអូរបស់អ្នកទីនេះ:

https://www.youtube.com/watch?v=WtPrzQTt1KI&t=1s

# ជំពូកទី៤

## សំណួរដែលត្រូវបានសួរជាញឹកញាប់

## បទពិសោធន៍ទទួលបាន និងកិច្ចសហប្រតិបត្តិការនាពេលអនាគត

## សំណួរដែលត្រូវបានសួរជាញឹកញាប់

### តើអ្នកណាជាអ្នកដែលទទួលបានអត្ថប្រយោជន៍សៀវភៅជំនួយនេះ?

កំឡុងពេលដែលមានជម្ងឺរាតត្បាតកូវីត១៩នេះយើងខ្ញុំបានធ្វើការបង្កើតនូវសៀវភៅជំនួយមួយក្បាលនេះឡើងមកដើម្បីធ្វើការណែនាំអំពីការធ្វើលំហាត់ប្រាណសម្រាប់កុមារពិការ ជម្ងឺផ្លូវចិត្តនឹងកុមារដែលចង់ធ្វើលំហាត់ប្រាណតែមិនអាចចេញទៅក្រៅបាន ។សៀវភៅជំនួយនេះនឹងធ្វើការណែនាំដល់មាតាបិតាដើម្បីលើកទឹកចិត្តដល់កូនៗអោយព្យាយាមធ្វើការហាត់ប្រាណនៅផ្ទះ។

### តើកម្មវិធី Zoom នឹងសៀវភៅជំនួយមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?

Zoom គឺជាប្រព័ន្ធអ៊ីនធឺណែតមួយដែលលើកកម្ពស់ផ្តល់ជូននូវចំណេះដឹង ជំនាញរបស់នរណាម្នាក់ទៅកាន់អ្នកដែលបានចូលរួមក្នុងការធ្វើសិក្ខាសិលាដែលបានរៀបចំដោយគម្រោងណាមួយជាក់លាក់។

សៀវភៅជំនួយនេះគឺជាឯកសារជាក់លាក់មួយដែលផ្តុកទៅដោយខ្លឹមសារសំខាន់ៗណាមួយទៅលើការធ្វើលំហាត់ប្រាណរូបរាងកាយ ។យើងបានបង្កើតសៀវភៅឯកសានេះក្នុងទម្រង់ជាឯកសាររឹង រឺឯកសារឌីជីថល។ វានឹងធ្វើការផ្សព្វផ្សាយព័ត៌មាននឹងធ្វើការណែនាំដល់មាតាបិតាអំពី វិធីចូលរួមធ្វើលំហាត់ប្រាណនៅផ្ទះអោយបានត្រឹមត្រូវ។

### តើយើងគួរធ្វើលំហាត់ប្រាណរាងកាយសម្រាប់កុមារពិការញឹកញាប់ប៉ុណ្ណា ?

ជាធម្មតា កុមារត្រូវការធ្វើលំហាត់ប្រាណរាងកាយចំនួន ៦០នាទីក្នុងមួយថ្ងៃ។ ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើលំហាត់ប្រាណរាងកាយគួរធ្វើវាយ៉ាងតិច៣ដងក្នុងមួយសប្តាហ៍។យ៉ាងហោចណាស់យើងគួរធ្វើការហាត់ប្រាណរាងកាយទៅតាមអ្វីដែលបានណែនាំនៅក្នុងសៀវភៅណែនាំយ៉ាងតិចចំនួន៣០នាទី។មាតាបិតាក៏គួរតែធ្វើការសង្កេតទៅលើកុមារថាពួកគេយកចិត្តទុកដាក់ក្នុងការធ្វើលំហាត់ប្រាណនេះបានទៅដល់កម្រិតណា។

### តើអ្វីទៅគឺជាគោលបំណងដ៏សំខាន់បំផុតក្នុងការធ្វើលំហាត់ប្រាណរាងកាយនិងលើកកម្ពស់សុខភាពកុមារពិការក្នុងរដូវកាលកូវីត ១៩នេះ ?

គោលបំណងចម្បងនេះគឺដើម្បីលើកទឹកចិត្តពួកគេអោយមានការផ្លាស់ទី ស្វែងរកនូវអ្វីដែលធ្វើអោយគេសប្បាយរីករាយ លើកកម្ពស់សុខភាពនឹងការចូលរួមក្នុងសកម្មភាពសង្គម នឹងដើម្បីបង្កើតអោយពួកគេបានញញឹមគ្រប់ពេលនៅក្នុងជីវិតប្រចាំថ្ងៃរបស់គេ។

## បទពិសោធន៍ទទួលបាន

1.ការវិភាគស្ថានភាពដ៏ត្រឹមត្រូវមួយត្រូវបានទាមទាដើម្បីអនុវត្តទិសក្នុងទិសដៅត្រឹមត្រូវដើម្បីដោះស្រាយបញ្ហាឬធ្វើការផ្លាស់ប្តូរជាវិជ្ជមាន។នេះតម្រូវអោយមានការប្រមូលព័ត៌មានត្រឹមត្រូវមួយអំពីបញ្ហានានាដូច្នេះយើងអាចឆ្លើយតបនូវដំណោះស្រាយចំពោះពួកគេប្រកបដោយប្រសិទ្ធភាព។

2.ការប្រើប្រាស់វេទិកាប្រជុំតាមប្រព័ន្ធអ៊ីនធឺណែត (ដូចជា zoom) បានក្លាយជាវិធីសាស្រ្តធម្មតាថ្មីមួយក្នុងការទំនាក់ទំនងនិងការផ្ទេរចំណេះដឹង។ ក្នុងនាមជាភ្នាក់ងារអនុវត្តសន្រាប់ការអភិវឌ្ឍសង្គម ឬផ្គត់ផ្គង់ក្រុមមនុស្សដែលងាយរងគ្រោះ យើងត្រូវរៀននិងប្រើប្រាស់ប្រព័ន្ធមួយនេះអោយបានច្បាស់លាស់។

3.សម្រាប់គម្រោងCEP,APCDដើរតួជាអ្នកសម្របសម្រួលក្នុងចំណោមដៃគូផ្សេងៗ(JICA,សាកលវិទ្យាល័យTsukuba ,សមាជិកនៃបណ្តាញអាស៊ានអូទីស្ស៊ឹមនិងបណ្តាញពិការភាពបញ្ញានៅតំបន់អនុតំបន់មេគ្គង)។APCD បានធ្វើការរួមបញ្ចូលគ្នានូវចំនុចខ្លាំងនិងសក្តានុពលនៃអង្គការដៃគូនីមួយៗដើម្បីធ្វើអោយគម្រោងទទួលបានជោគជ័យយ៉ាងឆាប់រហ័ស។

4.សៀវភៅជំនួយនេះនឹងដើរតួជាមគ្គុទេសមួយរូបសម្រាប់មាតាបិតានិងសមាជិកគ្រួសារដើម្បីធ្វើការជាមួយកូនៗរបស់ពួកគេក្នុងកំឡុងពេលកូវីត១៩នេះ។វិធីសាស្រ្តនេះក៏ជួយលើកកម្ពស់ទំនាក់ទំនងគ្រួសារនិងបង្កើន សម្ភារៈក្នុងស្រុក។

5.គម្រោងនេះជាគំរូមួយអំពីរបៀបធ្វើការជាមួយដៃគូនិងបណ្តាញផ្សេងៗនៅក្នុងប្រទេសជប៉ុននិងបណ្តាប្រទេសអាស៊ាន។វាអាចបង្ហាញពីការអនុវត្តល្អៗ លើការធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់ជនពិការនិងក្រុមងាយរងគ្រោះដទៃទៀតក្នុងកំឡុងពេលកូវីត១៩ នៅក្នុងតំបន់របស់យើង។

## កិច្ចសហប្រតិបត្តិការនាពេលអនាគត

1.ពង្រីកនិងផ្សព្វផ្សាយគំនិតនិងសៀវភៅជំនួយនៃគម្រោងនេះទៅកាន់តំបន់ធំៗ(តំបន់និងបណ្តាប្រទេសអាស៊ី-ប៉ាស៊ីហ្វិកផ្សេងទៀត) និងសហគមន៍ខ្នាតតូចនៃការងារ។

2.តាមរយៈការប្រើប្រាស់វិធីសាស្រ្តនិងក្របខ័ណ្ឌដូចគ្នាសម្រាប់គម្រោងនេះយើងអាចពង្រីកបន្ថែមលើបញ្ហាផ្សេងៗទៀត(ដូចជាសន្តិសុខស្បៀង ការកំសាន្តនិងកីឡា និងសុខភាពផ្លូវចិត្ត) ក៏ដូចជាអ្នកដែលនឹងទទួលបានផលផ្សេងទៀត (ក្រុមអ្នករងគ្រោះ)។

# ជំពូកទី៥

## មតិពីដៃគូនៃបណ្តាប្រទេសអាស៊ាន

**នេះគឺជារឿងរ៉ាវនិងចំណាប់អារម្មណ៍ពីអ្នកបានចូលរួមផ្ទាល់មួយចំនួននៅក្នុងបណ្តាប្រទេសអាស៊ាន។**

ខ្ញុំមានភាពសប្បាយរីករាយចិត្តយ៉ាងខ្លាំងនៅពេលដែលខ្ញុំបានធ្វើលំហាត់ប្រាណ។ (កុមារ អាយុ ៦ឆ្នាំ)

យើងគួរតែចែករំលែកអោយមាតាបិតាដទៃទៀតដែលជួបនិងបញ្ហាដូចគ្នានឹងយើងបានយល់ដឹង។ខ្ញុំសង្ឃឹមថា សកម្មភាពសិក្ខាសាលាបែបនេះគឺនៅតែបន្តបើទោះបីជាជម្ងឺពតត្បាតកូវីតនេះហើយក៏ដោយ។

(ឪពុកមួយរូប)
ប្រទេសកម្ពុជា

គំនិតផ្តួចផ្តើមនេះគឺជារបកគំហើញមួយ។វាផ្តល់អត្ថប្រយោជន៍ដល់ឪពុកម្តាយរបស់អ្នកដែលមានបញ្ហាអូទីស្សឹមនៅក្នុងប្រទេសឥណ្ឌូនេស៊ីនិងនៅទូទាំងបណ្តាប្រទេសអាស៊ាន។ សូម្បីតែក្នុងកំឡុងពេលនៃការរីករាលដាលនៃជម្ងឺកូវីត១៩ក៏ដោយ ក៏ការធ្វើសកម្មភាពរាងកាយមានភាពចាំបាច់សម្រាប់ការអភិវឌ្ឍដ៏ត្រឹមត្រូវ។សិក្ខាសាលាទាំងបីពិតជាអស្ចារ្យណាស់!

(សមាជិកគ្រួសារម្នាក់របស់កុមារដែលមានបញ្ហាអូទីស្សឹមនៅប្រទេសឥណ្ឌូនេស៊ី)
ប្រទេសឥណ្ឌូនេស៊ី

ការធ្វើលំហាត់ប្រាណនេះត្រូវបានរៀបចំមកយ៉ាងល្អនិងមានភាពងាយស្រួលក្នុងការធ្វើតាម។ខ្ញុំធ្វើលំហាត់ប្រាណជាមួយក្មេងប្រុសម្នាក់ដែលមានបញ្ហាអូទីស្សឹម។ខ្ញុំចូលចិត្តការធ្វើចលនា យូហ្គា និងល្បែងត្រិះ។ខ្ញុំមានគម្រោងនឹងចែករំលែកសៀវភៅជំនួយនេះទៅកាន់សហគមន៍ដែលមានបញ្ហាអូទីស្សឹមនេះនឹងមាតាបិតាដែលមានកូនមានបញ្ហានេះ។

(ឪពុកមួយរូប, ប្រធានសហគមន៍បញ្ហាអូទីស្សឹម)
ប្រទេសឡាវ

សិក្ខាសាលាទាំងអស់មាន៣ដែលខ្ញុំចូលចិត្ត។អ្វីដែលសំខាន់គឺ "ការចែករំលែកក្នុងចំណោមបណ្តាប្រទេសអាស៊ាន"។ កូនស្រីរបស់ខ្ញុំចូលចិត្តការហាត់យូហ្គា។ខ្ញុំនឹងធ្វើយូហ្គាដែលអាចអោយកូនស្រីរបស់ខ្ញុំងាយស្រួលក្នុងការហាត់ ហើយនាងក៏ចូលចិត្តលេងហ្គេមជាមួយនឹងថង់ថ្លាស្ទិចព្រោះវាមានភាពងាយស្រួលសម្រាប់នាង។

(មតិរបស់ម្តាយម្នាក់)
ប្រទេសម៉ាឡេស៊ី

ខ្ញុំពិតជាសប្បាយរីករាយយ៉ាងខ្លាំងនៅពេលបានទទួលការអញ្ជើញពី APCD ជាលើកដំបូងពីព្រោះវាជាវេលាមួយក៏លំបាកសម្រាប់ពួកយើងដែលត្រូវនៅផ្ទះនឹងរក្សារយៈចម្ងាយពីគ្នា។នេះជាការជួបជុំលក្ខណៈគ្រួសារដូចទៅនឹងសិក្ខាសាលាពីមុនផងដែរ។ក្នុងចំណោមការហាត់ប្រាណនេះខ្ញុំចូលចិត្តយូហ្គា។អ្នកអាចសំរាកនឹងកាត់បន្ថយស្ត្រេស។ខ្ញុំចង់ចែករំលែកបទពិសោធន៍និងចំណេះដឹងរបស់ខ្ញុំអំពីការហាត់យូហ្គានេះទៅកាន់ជនពិការទាំងអស់បានដឹង។ (សមាជិកក្រុមស្ម័គ្រចិត្ត)

**ប្រទេសមីយ៉ាន់ម៉ា**

ជាម្តាយមួយរូបប្រសិនបើកូនប្រុសរបស់ខ្ញុំសប្បាយចិត្តខ្ញុំក៏សប្បាយចិត្តផងដែរ។ ខ្ញុំបានឃើញកូនប្រុសរបស់ខ្ញុំខិតខំធ្វើលំហាត់ប្រាណ ហើយគាត់មានស្នាមញញឹមគ្រប់ពេលវេលាបែបនេះវាគ្រប់គ្រាន់ហើយសម្រាប់ខ្ញុំ។ (ម្តាយ)

ខ្ញុំបានរៀនពីរបៀបហាត់ប្រាណដោយប្រើប្រាស់ឧបករណ៍ដែលមាននៅក្នុងផ្ទះ។ ខ្ញុំគិតថានឹងចែករំលែកពីវិធីហាត់ប្រាណបែបនេះទៅកាន់អ្នកដទៃទៀតដែលដូចខ្ញុំ។ (ម្តាយមួយរូប)

**ប្រទេសហ្វីលីពីន**

ជនពិការផ្នែកចិត្តសាស្ត្រនិងក្រុមគ្រួសារអាចធ្វើលំហាត់ប្រាណជាមួយគ្នានៅផ្ទះតាមរយៈវេទិការជាក់ស្តែងពីចម្ងាយ។ សម្ភារៈសម្រាប់ចូលរួមមិនពិបាករកទេ។ មនុស្សម្នាក់ៗអាចយកទៅអនុវត្តធ្វើជាទម្លាប់នៃការហាត់ប្រាណរបស់ពួកគេដូចនេះខ្ញុំអាចមើលឃើញស្នាមញញឹមនៅលើមុខពួកគេ។ពួកគេមើលទៅសប្បាយរីករាយមានផាសុខភាពកក់ក្តៅនិងមិនមានអារម្មណ៍ខ្លាចកូវីត១៩នោះទេ។គម្រោងនេះពិតជាគួរអោយចាប់អារម្មណ៍ខ្លាំងណាស់។ (ប្រជាសហគមន៍ជំងឺផ្លូវចិត្តប្រចាំប្រទេសថៃ)

**ប្រទេសថៃឡង់ដ៏**

ខ្ញុំនឹងកូនស្រីរបស់ខ្ញុំចូលចិត្តលេងហ្គេមវាយសត្វចម្លែក ល្បែងត្រិះ ល្បែងរក្សាលំនឹងនិងល្បែងបោះជំហានទៅចំហៀង។
នាងសប្បាយរីករាយ ដូច្នេះខ្ញុំក៏សប្បាយរីករាយណាស់ដែរ។ (ម្តាយ)

ខ្ញុំចូលចិត្តហ្គេមវាយសត្វចម្លែកនិងល្បែងត្រិះបាល់ ខ្ញុំលេងជាមួយម៉ាក់នឹងប៉ារបស់ខ្ញុំវាពិតជាគួរអោយចាប់អារម្មណ៍ខ្លាំងណាស់។
(មតិផ្ទាល់ខ្លួនរបស់កុមារដែលមានបញ្ហាអូទីស្ស៊ឹម, អាយុ៣២ឆ្នាំ)

ការហាត់ប្រាណនេះមានភាពសាមញ្ញហើយងាយស្រួល។យើងមានគម្រោងធ្វើការហាត់ប្រាណនេះមួយសប្តាហ៍ម្តង។
(គ្រូបង្រៀនកុមារអូទីស្ស៊ឹម)

ការសិក្ខាសាលានេះមានភាពសប្បាយរីករាយណាស់។ខ្ញុំនឹងបង្រៀបកូនរបស់ខ្ញុំ។ (ម្តាយ)

ប្រទេសវៀតណាម

# សេចក្តីបន្ថែម ១:

## ឧទាហរណ៍៖ តើគួរដំណើរការសកម្មភាពសិក្ខាសាលាពីចំងាយតាមរបៀបណា?

នេះគឺជាសេចក្តីណែនាំក្នុងសកម្មភាព
រយៈពេល៦០នាទី

| | |
|---|---|
| ១.ជួបជុំគ្នា | |
| ២.ស្វាគមន៍ប្រកាសកាលវិភាគ | ៥នាទី |
| ៣.កម្តៅសាច់ដុំ | ១០នាទី |
| ៤.សកម្មភាពទី១ | ១៥នាទី |
| <សំរាក> | ៥នាទី |
| ៥.សកម្មភាពទី២ | ១៥នាទី |
| ៦.ការសម្រួលអារម្មណ៍ | ៥នាទី |
| ៧.ការឆ្លុះបញ្ចាំង | ៥នាទី |
| ៨.ក្នុងឱកាសលាគ្នា | |

### ការជួបជុំ

- ត្រូវប្រាកដថាអ្នកចូលរួមត្រូវបានជូនដំណឹងអោយចូលរួមលើវេទិកាប្រព័ន្ធអ៊ីនធឺណែតមុនពេលចាប់ផ្តើមសកម្មភាព
- អ្នកចូលរួមបានចូលរួមក្នុងវេទិកាអនឡាញ
- អ្នករៀបចំកម្មវិធីបង្ហាញកាលវិភាគនៅលើអេក្រង់។

### សេចក្តីស្វាគមន៍ ការជម្រាបជូនពីកាលវិភាគ

- វាគឺជាការចាប់ផ្តើមល្អជាមួយបរិយាកាសវិជ្ជមាន ប្រសិនបើសិក្ខាសាលាតែងតែចាប់ផ្តើមជាមួយ នឹងការស្វាគមន៍យ៉ាងសកម្មភាពបែបនេះ។
- អ្នកចូលរួមនឹងមានអារម្មណ៍ថាមានសុវត្ថិភាពត្រៀមខ្លួននិងសម្របខ្លួនទៅនឹងសកម្មភាពនៅ ពេលកាលវិភាគត្រូវបានចែករំលែកដល់មនុស្សគ្រប់គ្នានៅពេលចាប់ផ្តើម។

### ការកម្តៅសាច់ដុំ

- ការកម្តៅសាច់ដុំត្រូវបានអនុវត្តដើម្បីជៀសវាងរបួសណាមួយ។វាផ្តល់ជាយោបល់មួយដើម្បីអោយចេះ យកចិត្តទុកដាក់លើផ្នែកនៃរាងកាយដែលនឹងត្រូវបានប្រើក្នុងការធ្វើសកម្មភាពដ៏សំខាន់ណាមួយ។សូម មើលសៀវភៅជំនួយសម្រាប់ជាឧទាហរណ៍បន្ថែម។

### សកម្មភាព

- ត្រូវកំណត់ចំនួនសកម្មភាពបឋមដោយផ្អែកលើចំនួនពេលវេលាដែលអ្នកមាននិងចំនួនអ្នកចូលរួមដែលនិង តម្រូវចូលរួម។វាចាំបាច់ណាស់ដែលអ្នកហាត់ត្រូវសមជាមុនសិន ដើម្បីអ្នកអាចបែងចែកពេលវេលាចាំបាច់សម្រាប់ កិច្ចការនីមួយៗ។
- ផ្អែកលើឧបសគ្គនិងការចុះខ្សោយរបស់កូនអ្នក រាល់សកម្មភាពសំខាន់ៗគួរត្រូវជ្រើសរើសស្របតាមសៀវភៅណែនាំ។

### ការសម្រួលអារម្មណ៍

- សកម្មភាពនេះអាចជួយអោយកុមារបានសម្រាកនិងជៀសវាងការរមួលសាច់ដុំ។
- វាជាគំនិតល្អក្នុងការជ្រើសរើសការសម្រួលអារម្មណ៍មួយនេះដែលផ្តោតលើផ្នែកមួយនៃរាងកាយ ដែលត្រូវបានប្រើក្នុងសកម្មភាពសំខាន់ៗ។ ឧទាហរណ៍ខ្លះៗអាចស្វែងរកបាននៅក្នុងសៀវភៅជំនួយខាងលើ។

### ការឆ្លុះបញ្ចាំង

- សួរអ្នកចូលរួមថាតើសកម្មភាពមួយណាដែលពួកគេចូលចិត្តជាងគេហើយសកម្មភាពមួយណាដែលពិបាកសម្រាប់ពួកគេ ។ការបញ្ចេញមតិរបស់ពួកគេមានសារៈសំខាន់ណាស់សម្រាប់ការកែលម្អកម្មវិធី។
- ប្រសិនបើអ្នកអាចកែលម្អកម្មវិធិសម្រាប់ធ្វើកម្មភាពពេលក្រោយនោះអ្នកចូលរួមនឹងកាន់តែចាប់អារម្មណ៍និងបន្តចូលរួម។

### ក្នុងឱកាសលាគ្នា

- វាគឺជាគំនិតមួយដ៏ល្អដែលយើងគួរតែមានទម្លាប់មួយជាមួយគ្នានៅចុងបញ្ចប់នៃកម្មវិធីយើងគួរតែអោយពួកគាត់ច្រៀងចម្រៀងដែលពួកគាត់ចូលចិត្តជាមួយគ្នាឬថតរូបរួមនៅលើអេក្រង់ទូរស័ព្ទរឺកុំព្យូទ័ដែលអាចបង្កើនអោយកាន់តែមានបរិយាកាសសប្បាយរីករាយ ។ណាមួយវាក៏ជាការជូនដំណឹងមួយដែលធ្វើអោយអ្នកចូលរួមដឹងថាសកម្មភាពនេះត្រូវបានបញ្ចប់។

# សេចក្តីបន្ថែម២:

ឯកសារគោលគំនិតស្តីពីគម្រោង “ការលើកកម្ពស់ដល់ក្រុមឪពុកម្តាយរបស់កុមារដែលមានតម្រូវការពិសេសក្នុងកំឡុងពេលកូវីត១៩” ស្ថិតក្រោមកម្មវិធីនៃការលើកកម្ពស់សហគមន៍របស់ JICA

គិតត្រឹមថ្ងៃទី ២១ ខែមករា ឆ្នាំ ២០២១

# ការចង្អុលបង្ហាញ

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធជនពិការCRPD (មាត្រា៣១) ចែងថាជនពិការមានសិទ្ធចូលរួមដោយស្មើភាពជាមួយអ្នកដទៃក្នុងសកម្មភាពកម្សាន្ត ការលំហែនិងកីឡា ។គោលដៅទី៣គឺគោលដៅនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងការលើកកម្ពស់សុខភាពល្អនិងសុខមាលភាពសម្រាប់បនុស្សគ្រប់វ័យ ។ក្រុមងាយរងគ្រោះបានរងផលប៉ះពាល់ពីការផ្ទុះឡើងនៃកូវីត១៩គឺជាកុមារដែលមានតម្រូវការពិសេស (រួមមានមនុស្សដែលមានបញ្ហាអូទីស្សឹម,ពិការភាពបញ្ញា,ពិការភាពក្នុងការស្វែងយល់ និងពិការភាពផ្លូវចិត្ត) ។ក្នុងកំឡុងពេលបិទខ្ទប់ ច្បាប់នៃការរក្សាគម្លាតពីគ្នានៅក្នុងសង្គមធ្វើអោយពួកគេត្រូវនៅផ្ទះដោយគ្មានសកម្មភាពលំហាត់ប្រាណរាងកាយនិងទំនាក់ទំនងទៅក្នុងសង្គម ។ដើម្បីលើកកម្ពស់និងទឹកចិត្តក្នុងការរក្សាសុខភាពអោយល្អនិងសុខមាលភាពរបស់កុមារដែលមានតម្រូវការពិសេស APCD បានស្នើសុំការសហការជាមួយអ្នកផ្គត់ផ្គង់ធនធានជនជាតិជប៉ុនលើការកំសាន្ត ការលំហែ និងកីឡាដោយមានការចូលរួមដោយបង្កើតសៀវភៅជំនួយនិងឯកសារផ្សេងៗសម្រាប់ឪពុកម្តាយដែលមានកុមារមានតម្រូវការពិសេស ។បន្ថែមពីនេះក៏មានការដាក់បង្ហាញពីរបៀបដំណើរការដល់បណ្តាប្រទេសអាស៊ានជាពិសេសប្រទេសអនុតំបន់មេគង្គ ។

# ចំណងជើងគម្រោង

ស្ដីពីការលើកកម្ពស់ដល់ក្រុមឪពុកម្ដាយដែលមានកុមារមានតម្រូវការពិសេសក្នុងកំឡុងពេលកូវីត១៩

# អ្នកអនុវត្តគម្រោង

មជ្ឈមណ្ឌលអភិវឌ្ឍន៍អាស៊ីប៉ាស៊ីហ្វិកស្ដីពីពិការភាព (APCD)

វត្ថុបំណង

1. ដើម្បីលើកកម្ពស់ការចូលរួមរបស់សង្គមក្នុងចលនារាងកាយនិងការលើកកម្ពស់សុខភាពរបស់មនុស្សដែលមានតម្រូវការពិសេសក្នុងកំឡុងពេលនៃការផ្ទុះជម្ងឺកូវីត១៩។
2. ដើម្បីផ្លាស់ប្ដូរនិងចែករំលែកការអនុវត្តល្អៗពីដៃគូមកពីប្រទេសជប៉ុន ប្រទេសថៃ បណ្ដាប្រទេសក្នុងអនុតំបន់មេគ្គងនិងបណ្ដាប្រទេសអាស៊ាន ក្នុងការលើកកម្ពស់ចលនារាងកាយក្នុងកំឡុងពេលនៃការផ្ទុះជម្ងឺកូវីត១៩។
3. ដើម្បីពង្រឹងកិច្ចសហការនិងបណ្ដាញរវាងភាគីពាក់ព័ន្ធសម្រាប់កិច្ចសហប្រតិបត្តិការនិងការអនុវត្តនាពេលអនាគតទៅលើការអភិវឌ្ឍន៍កុមារដែលមានតម្រូវការពិសេសតាមរយៈការបង្កើតកម្មវិធីថ្មីតាមអ៊ីនធឺណែតស្ដីពីកម្មវិធីលើកម្ពស់កំឡុងពេលនៃការផ្ទុះជម្ងឺកូវីត១៩។
4. ដើម្បីសង្កេតការបោះពុម្ពផ្សាយនិងបង្ហាញពីរបៀបអនុវត្តចលនារាងកាយដែលសម្របខ្លួនជាមួយនឹងវិធីសាស្ត្រច្នៃប្រឌិតដើម្បីលើកកម្ពស់គុណភាពជីវិតរបស់បុគ្គលដែលមានតម្រូវការពិសេសក្នុងកំឡុងពេលនៃការផ្ទុះជម្ងឺកូវីត១៩។

## លទ្ធផលរំពឹងទុក

1. ការចូលរួមរបស់សង្គមក្នុងចលនារាងកាយនិងការលើកកម្ពស់សុខភាពរបស់បុគ្គលដែលមានតម្រូវការពិសេសត្រូវបាន ផ្សព្វផ្សាយក្នុងកំឡុងពេលនៃការផ្ទុះជម្ងឺកូវីដ១៩។

2. ការអនុវត្តរបស់ដៃគូពីប្រទេសជប៉ុនដល់បណ្តាប្រទេសអាស៊ានជាពិសេសបណ្តាប្រទេសនៅអនុតំបន់មេគ្គងក្នុងការក្នុងការ លើកកម្ពស់ចលនារាងកាយត្រូវបានផ្លាស់ប្តូរនិងចែករំលែកក្នុងកំឡុងពេលនៃការផ្ទុះជម្ងឺកូវីដ១៩។

3. ការសហការនិងការបង្កើតបណ្តាញទំនាក់ទំនងរវាងភាគីពាន់ព័ន្ធសម្រាប់កិច្ចសហប្រតិបត្តិការនិងការអនុវត្តនាពេលអនាគតទៅ ការអភិវឌ្ឍកុមារដែលមានតម្រូវការពិសេសតាមរយៈការបង្កើតថ្មីតាមអ៊ីនធឺណែតស្តីពីកម្មវិធីលើកកម្ពស់ ត្រូវបានពង្រឹងក្នុងកំឡុង ពេលនៃការផ្ទុះជម្ងឺកូវីដ១៩។

4. ការបោះពុម្ពផ្សាយនិងការបង្ហាញអំពីវិធីអនុវត្តចលនារាងកាយដែលសម្របខ្លួនជាមួយនឹងវិធីសាស្ត្រច្នៃប្រឌិតដើម្បីលើកកម្ពស់ គុណភាពជីវិតរបស់បុគ្គលដែលមានតម្រូវការពិសេសត្រូវបានមកប្រែនិងផលិតក្នុងកំឡុងពេលនៃការផ្ទុះជម្ងឺកូវីដ១៩។

### គោលដៅ

មនុស្សជាង២០០០ នាក់រួមទាំងអ្នកដែលមានតម្រូវការពិសេសឪពុកម្តាយសមាជិកគ្រួសារនិងអាណាព្យាបាលនឹងទទួលបានអត្ថ ប្រយោជន៍តាមរយៈសិក្ខាសាលាដែលបង្ហាញតាមអ៊ីធឺណែតនិងការផ្សព្វផ្សាយការបោះពុម្ពផ្សាយ។ អ្នកពាក់ព័ន្ធនៃគម្រោងមានដូចជា៖

### ប្រទេសជប៉ុន

- សង្គមមនុស្សមានអូទីស្សឹមប្រទេសជប៉ុន (ASJ)
- សាកលវិទ្យាល័យ TSUKUBA
- អង្គការជប៉ុនផ្សេងៗទៀតដែលបានធ្វើការជាមួយនិងដើម្បីសកម្មភាពរាងកាយដែលត្រូវបានសម្រួលសម្រាប់អ្នកដែល មានអូទីស្សឹមនិងពិការសតិបញ្ញា។

# បណ្តាប្រទេសក្នុងតំបន់អាស៊ាន

- បណ្តាអ្នកមានអូទីស្សឹមក្នុងបណ្តាប្រទេសអាស៊ាន (AAN)

- (SMARTER) របស់ប្រទេសព្រុយណេ
- បណ្តាញអូទីស្សឹមកម្ពុជា ( CAN ), ប្រទេសកម្ពុជា
- Yayasan អូទីស្សឹមឥណ្ឌូនេស៊ី ( YAI ), ប្រទេសឥណ្ឌូនេស៊ី
- បណ្តាញអូទីស្សឹមឡាវ ( AfA នៅក្នុងប្រទេសឡាវ )
- សមាគមន៍ជាតិអូទីស្សឹមម៉ាឡេស៊ី ( NASOM ), ប្រទេសម៉ាឡេស៊ី
- សមាគមន៍អូទីស្សឹមមីយ៉ាន់ម៉ា ( MAA) , ប្រទេសមីយ៉ាន់ម៉ា
- សង្គមអ្នកមានអូទីស្សឹមហ្វីលីពីន ( ASP )
- បណ្តាញអូទីស្សឹមសិង្ហបុរី ( ASP ), ប្រទេសសិង្ហបុរី
- សមាគមឪពុកម្តាយជនជាតិថៃដែលមានអូទីស្សឹម ( AU Thai )
- បណ្តាញអូទីស្សឹមវៀតណាម ( VAN ), ប្រទេសវៀតណាម

## បណ្តាប្រទេសក្នុងអនុតំបន់មេគង្គ

- បណ្តាញសហព័ន្ធ ( ពិការសតិបញ្ញា ) - បណ្តាញនៅមហាអនុតំបន់មេគង្គ
បណ្តាញក្រុមតស៊ូមតិដោយខ្លួនឯងនៃជនពិការសតិបញ្ញាដែលមកពី៖

- ប្រទេសកម្ពុជា ( ក្រុមកុលាប )
- ប្រទេសឡាវ ( ក្រុមទេពកោសល្យ )
- ប្រទេសមីយ៉ាន់ម៉ា ( ក្រុមអនាគតផ្កាយនិងក្រុមផ្កាយព្រឹក )
- ប្រទេសថៃ ( ក្រុមដាវរូង )
- ប្រទេសវៀតណាម (ក្រុមអនាគតរបស់ខ្ញុំ )

- ផ្សេងៗទៀត

- សមាគមន៍ជនពិការភាពបញ្ញានៅប្រទេសថៃ (A P I D T H )
- សមាគមន៍ជម្ងឺផ្លូវចិត្តនៅប្រទេសថៃ និងអង្គការផ្សេងៗទៀតដើម្បីជនពិការភាពផ្លូវចិត្តនៅបណ្តាប្រទេសក្នុងអាស៊ាន។

# វិធីសាស្ត្រ

១. ការបកប្រែសំណួរទៅជាភាសាផ្លូវការរបស់សមាជិកអាស៊ាន
២. ការដឹកនាំសំណួរតាមអ៊ីនធឺណែត
៣. ការបកប្រែសកម្មភាព ចលនាកាយផ្ទះសម្រាប់កុមារដែលមានតម្រូវការពិសេស។ (កំណែជប៉ុនប្រែជាភាសាអង់គ្លេស )
៤. ការធ្វើបទសម្ភាសន៍តាមអ៊ីនធឺណែត ( បើចាំបាច់ )
៥. ផ្លាស់ប្តូការសិក្សាករណី និងការអនុវត្តល្អ
៦. ប្រព្រឹត្តទៅសិក្ខាសាលាតាមអនឡាញ
៧. ការវិភាគទិន្នន័យ និងព័ត៌មាន
៨. បកប្រែសៀវភៅដៃចុងក្រោយទៅជាភាសាជាតិរបស់អាស៊ាន
៩. ការរៀបចំរបាយការណ៍សកម្មភាព
១០. ការចែកចាយសៀវភៅណែនាំទៅកាន់បណ្តាប្រទេសអាស៊ាន។

**អ្នករៀបចំកម្មវិធី**

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
មជ្ឈមណ្ឌលពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (APCD)
សាកលវិទ្យាល័យ TSUKUBA

**សហការជាមួយ**

បណ្តាញអ្នកមានអូទីស្សឹមក្នុងបណ្តាប្រទេសអាស៊ាន (AAN)
បណ្តាញពិការភាពបញ្ញានៅតំបន់អនុតំបន់មេគង្គ (United ID Mekong Network)
សមាគមថៃសម្រាប់ជំងឺផ្លូវចិត្ត (AMIT)
សមាគមថៃសម្រាប់ជនពិការបញ្ញា (APIDTH)
សមាគមថៃបង្រួបបង្រួមអ្នកមានអូទីស្ស៊ី(AU)
សង្គមអ្នកមានអូទីស្សឹមប្រទេសជប៉ុន (ASJ)